ថ្ងៃទី19 ខែកុម្ភៈ ឆ្នាំ2020

# អំពីសេវាពិគ្រោះទាក់ទងនឹងវីរុសកូរ៉ូណាប្រភេទថ្មី

## បញ្ជរពិគ្រោះ (មជ្ឈមណ្ឌលពិគ្រោះសម្រាប់អ្នកធ្វើមាតុភូមិនិវត្តន៍និងអ្នកប៉ះពាល់)

ដើម្បីបំបាត់នូវក្តីបារម្ភរបស់ប្រជាពលរដ្ឋក្នុងខេត្តទាក់ទងនឹងការកើតឡើងនៃជំងឺឆ្លងវីរុសកូរ៉ូណាប្រភេទថ្មីនាពេលបច្ចុប្បន្ននេះ យើងខ្ញុំបានបង្កើតនូវបញ្ជរពិគ្រោះតាមទូរស័ព្ទដូចខាងក្រោម។



| | | |
|---|---|---|
| ទីស្នាក់ការសុខាភិបាល | មជ្ឈមណ្ឌលសុខុមាលភាពអ៊ីវ៉ាគុនិ | 0827－29－1523 |
| | មជ្ឈមណ្ឌលសុខុមាលភាពយ៉ាណាយ | 0820－22－3631 |
| | មជ្ឈមណ្ឌលសុខុមាលភាពស៊ីណាំង | 0834－33－6423 |
| | មជ្ឈមណ្ឌលសុខុមាលភាពយ៉ាម៉ាហ្គុឈិ | 083－934－2533 |
| | មជ្ឈមណ្ឌលសុខុមាលភាពយ៉ាម៉ាហ្គុឈិ សាខាហូហ្វុ | 0835－22－3740 |
| | មជ្ឈមណ្ឌលសុខុមាលភាពអ៊ុបិ | 0836－31－3203 |
| | មជ្ឈមណ្ឌលសុខុមាលភាពណាហ្កាតុ | 0837－22－2811 |
| | មជ្ឈមណ្ឌលសុខុមាលភាពហាហ្គិ | 0838－25－2667 |
| | ទីស្នាក់ការសុខាភិបាលស៊ីម៉ូណូសិគិប្រចាំក្រុងស៊ីម៉ូណូសិគិ * | 083－250－7778 |
| | នាយកដ្ឋានជម្រុញសុខាមាលភាពខេត្ត * | 083－933－3502 |

[ម៉ោងទទួលទូរស័ព្ទ] 9:00 ~ 17:00 (អាចឆ្លើយតបជាភាសាច្រើន)

*សម្រាប់ថ្ងៃសៅរ៍ អាទិត្យនិងថ្ងៃបុណ្យជាតិ នាយកដ្ឋានជម្រុញសុខាមាលភាពខេត្តនឹងឆ្លើយតបទូរស័ព្ទ ហើយចំពោះប្រជាជនក្នុងក្រុងស៊ីម៉ូណូសិគិនឹងត្រូវទទួលការឆ្លើយតបទូរស័ព្ទពីទីស្នាក់ការសុខាភិបាលស៊ីម៉ូណូសិគិប្រចាំក្រុងស៊ីម៉ូណូសិគិ។

## ចំពោះការពិគ្រោះតាមទូរស័ព្ទពីអ្នកធ្វើមាតុភូមិនិវត្តន៍និងអ្នកប៉ះពាល់
### (មជ្ឈមណ្ឌលពិគ្រោះសម្រាប់អ្នកធ្វើមាតុភូមិនិវត្តន៍និងអ្នកប៉ះពាល់)

ករណីអ្នកមានរោគសញ្ញានិងសង្ស័យថាកំពុងកើតមានជំងឺឆ្លងវីរុសកូរ៉ូណាប្រភេទថ្មី
មុននឹងអ្នកទៅទទួលការពិនិត្យ សូមលោកអ្នកទូរស័ព្ទមកកាន់ ទីស្នាក់ការសុខាភិបាល ដែលនៅក្បែរលោកអ្នកជាងគេតាមលេខទំនាក់ទំនងខាងលើ កុំខកខានអោយសោះ។

ករណីបន្ទាន់ យើងខ្ញុំក៏ទទួលការពិគ្រោះក្រៅម៉ោងទទួលទូរស័ព្ទខាងលើផងដែរ។ ម្យ៉ាងទៀត ករណីចាំបាច់ យើងខ្ញុំនឹងណែនាំស្ថាប័នផ្តល់សេវាសុខភាពជូនដល់លោកអ្នក។



○ អ្នកដែលបន្តមានរោគសញ្ញាផ្តាសាយនិងអាការៈក្តៅខ្លួនចាប់ពី 37.5 អង្សាឡើងទៅ រយៈពេល 4 ថ្ងៃឬយូរជាងនេះ (ដូចគ្នាដែរចំពោះអ្នកដែលមានអាការៈនិងត្រូវពិសាថ្នាំបញ្ចុះកម្តៅជាបន្តបន្ទាប់)
○ អ្នកដែលមានអាការៈពោយខ្លួនខ្លាំង (អស់កម្លាំង) និង ដកដង្ហើមមិនស្រួល (ពិបាកដកដង្ហើម)
*ចំពោះមនុស្សចាស់ និង អ្នកដែលមានជំងឺទឹកនោមផ្អែម ឬ ជំងឺខ្សោយមុខងារបេះដូង ឬ ជំងឺទាក់ទងនឹងផ្លូវដង្ហើម (ជំងឺCOPD ជាដើម) ឬ អ្នកដែលកំពុងប្រើប្រាស់ឱសថទប់ស្កាត់ប្រព័ន្ធការពាររាងកាយឬឱសថព្យាបាលជំងឺមហារីក សូមទំនាក់ទំនងមកកាន់យើងខ្ញុំដើម្បីពិគ្រោះ ប្រសិនមានរោគសញ្ញាខាងលើរយៈពេលប្រហែល2ថ្ងៃ។
* ចំពោះស្ត្រីមានផ្ទៃពោះ ដើម្បីបង្ការ សូមធ្វើការពិគ្រោះអោយបានឆាប់រហ័ស។

<ចំណុចដែលអ្នកគួរចងចាំមុននឹងធ្វើការពិគ្រោះឬទៅទទួលការពិនិត្យ>

・នៅពេលអ្នកចាប់ផ្តើមមានរោគសញ្ញាផ្តាសាយដូចជាក្តៅខ្លួនជាដើម សូមអ្នកឈប់សម្រាកពីសាលារៀនឬក្រុមហ៊ុន និង ចៀសវាងចេញក្រៅផ្ទះ។

・នៅពេលអ្នកកំពុងមានរោគសញ្ញាផ្តាសាយដូចជាក្តៅខ្លួនជាដើម សូមអ្នកវាស់កម្តៅនិងកត់ត្រាទុកជារៀងរាល់ថ្ងៃ។

សូមអ្នកស្វែងរកព័ត៌មានថ្មីៗអំពីជំងឺឆ្លងវីរុសកូរ៉ូណាប្រភេទថ្មីនៅគេហទំព័រនៃក្រសួងសុខាភិបាល ការងារនិងសុខុមាលភាព។

**ខេត្តយ៉ាម៉ាហ្គុឈិ**

ក្រសួងសុខាភិបាល ការងារនិងសុខុមាលភាព ទាក់ទងនឹង វីរុសកូរ៉ូណាប្រភេទថ្មី